# សេចក្តីថ្លែងការណ៍
# ស្តីពី
# បញ្ហា និងការប្រឈមរបស់ស្ត្រីជនជាតិដើមភាគតិចលើការអនុវត្តច្បាប់ និងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

## សណ្ឋាគារ ហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០២៣

**នៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី** សហគមន៍ និងអង្គការសមាគមជនជាតិដើមភាគតិចសរុប ចំនួន **៤៨នាក់** ក្នុងនេះក្រុមស្ត្រីជនជាតិដើមភាគតិចចំនួន **៣៦ នាក់**ដែលមានជាតិពន្ធដូចជា **គ្រឹង ទំពួន កួយ ព្នង ចារាយ ថ្មូន ព៉ារ ស្អូយ ជង ស្អូច** មកពីខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ កំពង់ធំ កំពង់ស្ពឺ ពោធិ៍សាត់ កំពង់សោម កោះកុង និងខេត្តបាត់ដំបងបានរៀបចំវេទិការពិគ្រោះយោបល់ថ្នាក់ជាតិរបស់ខ្លួនស្តីពី "**បញ្ហា និងការប្រឈមរបស់ស្ត្រីជនជាតិដើមភាគតិចលើការអនុវត្តច្បាប់ និងសេចក្តីព្រាងច្បាប់ថ្មីពីរ ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ** " ព្រមទាំងវត្តមានតំណាងក្រសួងមកពីរាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងអ្នកសារព័ត៌មាន។

យើងខ្ញុំជាក្រុមស្ត្រី តំណាងសហគមន៍ និងអង្គការសមាគមជនជាតិដើមភាគតិច សូមថ្លែងអំណរគុណដល់ឯឧត្តម លោកជំទាវតំណាង ក្រសួង តំណាងរាស្ត្រ ព្រឹទ្ធសភា អាជ្ញាធរខេត្ត លោកជំទាវ ស្ត្រីភ្ញៀវជាតិនិងអន្តរជាតិ ដែលបានផ្តល់កិត្តិយសចូលរួមក្នុងវេទិការពេញមួយថ្ងៃនេះ ។ ក្នុងឱកាសនេះ យើងខ្ញុំក៏សូមធ្វើការថ្លែងនូវទុក្ខកង្វល់ បញ្ហាដែលបាននិងកំពុងប្រឈម ទាំងកំរិតឯកជន និងទាំងកំរិតសហគមន៍ជារួម និងសំណូមពរ ដូចខាង ក្រោម ៖

១- ការបាត់បង់សិទ្ធិលើដីធ្លី និងធនធានធម្មជាតិ ពីជម្លោះទាស់ទែងជាមួយក្រុមហ៊ុនឯកជន និងបុគ្គលឯកជនទៅពីឆ្វាយចាប់យក ឬទិញលក់ដីសហគមន៍។ ការបាត់បង់នេះ បានបណ្តាលឲ្យជីវភាពជនជាតិដើមភាគតិចយើងខ្ញុំជួបការលំបាក និងបាត់បង់មុខរបរប្រពៃណី ទំនៀមទម្លាប់ បាត់ភាសា និង បាត់បង់ការរស់នៅសុខសាន្ត ហើយប្រឈមនឹងទំនាស់ទាស់ទែងគ្នាខាងក្នុង និងប្រឈមនឹងការប្តឹង តាមផ្លូវតុលាការ។ ក្រោយពីការពិភាក្សាក្នុងវេទកាថ្ងៃនេះ បង្ហាញបន្ថែមថាមានកង្វះខាតការទទួលស្គាល់សិទ្ធិប្រពៃណី ដែលជាសិទ្ធិសង្គម និងវប្បធ៌មរបស់ជនជាតិដើមភាគតិចក្នុងការអនុវត្តជាក់ស្តែង និងការយឺតយ៉ាវក្នុងការចេញ ប្លង់កម្មសិទ្ធិសមូហភាពឲ្យទាន់ពេលវេលា។

២- អាជ្ញាធរក្រោមជាតិក្នុងខេត្តមួយចំនួនមានការរើសអើង ដោយបានបដិសេធមិនទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិច ហើយការបដិសេធនេះ បានក្លាយជាឱកាសដល់អ្នកខាងក្រៅទន្ទ្រានឬទិញយកដីពី សមាជិកសហគមន៍ និងរាំងស្ទះដល់ដំណើរការកំណត់អត្តសញ្ញាណ និងចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពស្របតាមច្បាប់កំណត់ ។

៣- រហូតដល់ថ្ងៃវេទិកានេះ មានស្ត្រីជនជាតិដើមភាគតិចជាច្រើននាក់បាននឹងកំពុងស្ថិតក្នុង នីតិវិធីតុលាការ ដែលជាប់សង្ស័យ និងជាប់ចោទ ដែលប្រឈមនឹងទោសជាប់ពន្ធនាគារ និង សំណងជាប្រាក់ច្រើនពាន់ដុល្លាអាមេរិក ដែលរឿងនេះធ្វើឱ្យពួកយើងខ្ញុំមានការព្រួយបារម្ភណ៍ជាខ្លាំង។ ដូចបានលើកឡើងក្នុងវេទិកាថ្ងៃនេះ សកម្មភាពការពារមុខរបរក្នុងព្រៃ ការពារជំនឿក្នុងព្រៃ លើភ្នំ ទីតាំងជំនឿ បានប្រឈមនឹងផ្លូវច្បាប់ជាតិដែលយើងខ្ញុំមិនចេះ និងមិនយល់។ ស្ត្រីជនជាតិដើមភាគតិចជាច្រើនដែលបាន ចូលរួមក្នុងវេទីកា ថ្ងៃនេះគឺកំពុងតែស្ថិតក្នុង សំណុំរឿងព្រហ្មទណ្ឌយ៉ាងតិច **៤២** ដែលទាក់ទងនឹងសិទ្ធិលើសង្គម

សិទ្ធិវប្បធ៌ម សិទ្ធិសេដ្ឋកិច្ចជាមុខរបរប្រពៃណីជាប់នឹងទីតាំងក្នុងដីដែលយើងខ្ញុំ សូមរៀបរាប់តាមករណី និងតាមខេត្តនីមួយៗដូចខាងក្រោមៈ

ខេត្តព្រះវិហារចំនួន ០៣ សំណុំរឿង

ខេត្តកំពង់ធំ ចំនួន ០៦ សំណុំរឿង

ខេត្តស្ទឹងត្រែង ចំនួន ០១ សំណុំរឿង

ខេត្តមណ្ឌលគីរីចំនួន ២៩ សំណុំរឿង

ខេត្តរតនគីរីចំនួន ២ សំណុំរឿង

ខេត្តក្រចេះចំនួន ០១ សំណុំរឿង

យើងខ្ញុំសូមថ្លែងនូវការស្វាគមន៍ និងត្រេកអរដែលសាលាដំបូងខេត្តមណ្ឌលគីរីបានសម្រេចលើកបទចោទលើជនជាតិដើមភាគិតិចចំនួន ៤នាក់ ហើយតុលាការកំពូលក៏បានសម្រេចផ្តល់យុត្តិធ៌មដល់ស្ត្រីជនជាតិដើមភាគតិចពួងចំនួន ០៣នាក់កន្លងមកដែលនេះជាផ្នែកមួយនៃយុត្តិធ៌មដែលស្ត្រីយើងខ្ញុំទទួលបាន។

៤- យើងខ្ញុំជាស្ត្រីដែលបានការពារសិទ្ធិរបស់ខ្លួន និងសហគមន៍លើដីធ្លី ធនធានធម្មជាតិ ត្រូវបានកោះហៅដោយអាជ្ញាធរឃុំ នគរបាល កងរាជអាវុធហត្ថ អាជ្ញាធរស្រុក អាជ្ញាធរខេត្តមួយចំនួនទៀតជាច្រើនករណីដែលយើងខ្ញុំមានទុក្ខកង្វល់ជាខ្លាំង ពីព្រោះយើងខ្ញុំធ្លាប់រងសម្ពាធជាច្រើន។

៥- ការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តកន្លងមកដូចខាងលើនេះ ស្ត្រីជនជាតិដើមភាគតិចមានក្តីព្រួយបារម្ភ ឬមានទុក្ខកង្វល់យ៉ាងខ្លាំងទៅលើបែបបទនៃការអនុវត្តដែលស្មុកស្មាញ ខ្វះមន្ត្រីអនុវត្តន៍ ហើយជាពិសេស គឺមិនមានការពិគ្រោះយោបល់ត្រឹមត្រូវ និងមិនមានការចូលរួមសម្រេចពីតំណាងសហគមន៍ ចាស់ទុំដែលជាបណ្ណាល័យរស់របស់សហគមន៍យើងខ្ញុំ និងជាអ្នកដឹងពីច្បាប់ទំនៀមទម្លាប់ និងប្រពៃណី។ ការបាត់បង់វិធានប្រពៃណី គឺជាការប្រឈមរបស់យើងខ្ញុំ ។

៦- យើងខ្ញុំសូមថ្លែង នូវការបន្តគាំទ្រដល់សេចក្តីថ្លែងការណ៍ស្តីពីធាតុចូលរបស់តំណាងជនជាតិដើមភាគតិចកាលពីថ្ងៃទី **១៥-១៦ ខែសីហា ឆ្នាំ ២០២២** នៅខេត្តសៀមរាបទាំងស្រុង ។

ហេតុដូច្នេះយើងខ្ញុំជាក្រុមស្ត្រី និងជាតំណាងសហគមន៍ជនជាតិដើមភាគតិចដែលចូលរួមក្នុងវេទិការថ្ងៃនេះ សូមលើកជាសំណើ និងធ្វើការអំពាវនាវដូចខាងក្រោមៈ

១- សូមឱ្យចាត់ទុកសង្គមសហគមន៍ជនជាតិដើមភាគតិចជាសង្គមអចិន្ត្រៃយ៍ មានសិទ្ធិស្វ័យអភិវឌ្ឍន៍ដែលរក្សាបានអត្តសញ្ញាណរបស់យើងខ្ញុំជាជនជាតិដើមភាគតិចតាមរយៈច្បាប់ និងគោលនយោបាយដែលមានការទទួលស្គាល់នូវលក្ខណៈដោយឡែកពីកំណើត និងធានាបាននូវសិទ្ធិសមូហភាពក្នុងក្របខណ្ឌច្បាប់ និងបទដ្ឋានជាតិ និងអន្តរជាតិ។

២- សូមរាជរដ្ឋាភិបាលពន្លឿនដំណើរការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពតាមទំហំ និងព្រំប្រទល់ដែលសហគមន៍បង្ហាញជាក់ស្តែង ហើយផ្នែកខ្លះជាដីព្រៃរបស់រដ្ឋដែលយើងខ្ញុំជាអ្នកគ្រប់គ្រង និងការពារ រួមគ្នាជាមួយអាជ្ញាធរមានសមត្ថកិច្ច។ ការចុះបញ្ជីដីកន្លងមកនេះគឺបានតែដីចំនួន ៥ប្រភេទប៉ុណ្ណោះ ហើយផាត់ដីរដ្ឋដែលយើងខ្ញុំការពារ និងពឹងអាស្រ័យផលនៅក្រៅដីកម្មសិទ្ធិសមូហភាព ជាពិសេស ការកំណត់ទំហំដីព្រៃអារក្សត្រឹម៧ហិកតាដែលធ្វើឱ្យប៉ះពាល់ដល់ជំនឿរបស់យើងខ្ញុំ។ សហគមន៍យើងភាគច្រើនគឺមានជំនឿលើ ភ្នំអារក្ស ទាំងមូល ដែលមិនបានកំណត់ជាទំហំនៃហិកតានោះទេ ។

៣- សំណូមពរអាជ្ញាធរក្រោមជាតិ ជួយពន្លឿនការចេញលិខិតរដ្ឋបាល និងបញ្ជូនលិខិតទាំងនោះទៅថ្នាក់ជាតិ ឬក្រសួង ដើម្បីពន្លឿន និងកុំឲ្យមានការរាំងស្ទះ និងយឺតយ៉ាវ ។

៤- ស្នើសុំឱ្យមានការសម្រេចទម្លាក់បទចោទប្រកាន់ និងសម្រេចបញ្ចប់ការចោទប្រកាន់ដូចមាន ក្នុងសំណុំរឿងនៅតុលាការ ពាក់ព័ន្ធនឹងស្ត្រី និងសមាជិកសហគមន៍ជនជាតិដើមភាគតិច ឲ្យបានឆាប់តាមនីតិវិធី ។

៥- ស្នើសុំឱ្យអាជ្ញាធរខេត្តចេញវិធានការការពារបណ្តោះអាសន្ន ឬលិខិតទទួលស្គាល់ ឬលិខិតបញ្ជាក់នូវ ដីតំបន់ជំនឿសាសនា វប្បធម៌ ទំនៀមទម្លាប់ និងដីតំបន់ ដើមឈើ បឹងត្រពាំងដែលជាប្រភពសេដ្ឋកិច្ច និងទីផ្សារ ជីវភាពប្រចាំថ្ងៃរបស់សហគមន៍ ជនជាតិដើមភាគតិច ក្នុងពេលរង់ចាំការចុះបញ្ជីដី ឬចុះបញ្ជីអត្តសញ្ញាណសហគមន៍ជាផ្លូវការ ។

៦- សេចក្តីព្រាងវិសោធនកម្មច្បាប់ច្បាប់ស្តីពីព្រៃឈើ និងសេចក្តីព្រាងវិសោធនកម្មច្បាប់ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ សូមបញ្ចូលនូវគ្រប់ចំណុច ដែលបានថ្លែងក្នុងសេចក្តីថ្លែងការណ៍ ដែលបានធ្វើឡើងនៅខេត្តសៀមរាប កាលពីថ្ងៃទី **១៥-១៦ ខែសីហា ឆ្នាំ២០២២** និងសូមបន្ថែមចំណុចមួយចំនួនទៀតដូចខាងក្រោម ៖

- គួរមានបែបបទនៃការទទួលស្គាល់ក្រុមដែលមានស្រាប់ក្នុងកម្រិតថ្នាក់ក្រោមជាតិ មុនដំណើរការចុះបញ្ជី ក្នុងគោលដៅបន្តការគ្រប់គ្រងសហគមន៍ ដីធ្លី និងធនធានធម្មជាតិ ។
- គួរមានបញ្ញត្តិទោសដល់អ្នកបំពានសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល មុនពេលដី និងសហគមន៍ទទួលបានការចុះបញ្ជីផ្លូវការ ។
- អភិបាលកិច្ចលើមុខរបរប្រពៃណី ទោះបីមិនមានបណ្ណកម្មសិទ្ធិក៏ដោយ ។

៧- យើងខ្ញុំសូមទទូចរក្សាពាក្យ “ជនជាតិដើមភាគតិច” “សហគមន៍ជនជាតិដើមភាគតិច” ក្នុងច្បាប់ទាំងពីរនេះ ។ ការដកចេញនូវពាក្យជនជាតិដើមភាគតិចដោយជំនួសដោយពាក្យ “សហគមន៍មូលដ្ឋាន” គឺជាការព្រួយបារម្ភរបស់យើងខ្ញុំបំផុតពីព្រោះនាំឲ្យបាត់បង់ឱកាស និងសិទ្ធិផ្សេងៗទៀតដែលយើងខ្ញុំមានពីកំណើត និង ចែងក្នុង សេចក្តីប្រ កាសអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច ។

៨- សូមស្នើសុំឱ្យសេចក្តីព្រាងវិសោធនកម្មច្បាប់ជលផលដែលយើងខ្ញុំមិនទាន់បានចូលរួម ពិចារណាដាក់ជាតុចូលដូចធាតុចូលស្នើសម្រាប់ច្បាប់ទាំងពីរដែរ ។

៩- សូមអំពាវនាវដល់អង្គការរដ្ឋ អង្គការជាតិ អង្គការអន្តរជាតិ អង្គការសហប្រជាជាតិ ផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀតក្នុងការអនុវត្តច្បាប់ គោលការណ៍ និងបទដ្ឋានជាតិ អន្តរជាតិដែលជាមូលដ្ឋានគាំទ្រដល់ជនជាតិដើមភាគតិច ក្នុងការធានានូវការអភិវឌ្ឍដោយបរិយាប័ន។

ជាទីបញ្ចប់ យើងខ្ញុំជាស្ត្រីជនជាតិដើមភាគតិច និងជាតំណាងសហគមន៍ជនជាតិដើមភាគតិច សូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចូលរួមក្នុងវិទិកាពិគ្រោះយោបល់ថ្នាក់ជាតិថ្ងៃនេះ និងសូមឲ្យដួងព្រលឹងដូនតា បុព្វបុរស របស់ជនជាតិដើមភាគតិចជូនពរ និងថែរក្សា ឯកឧត្តម លោកជំទាវ លោក លោកស្រី ឱ្យទទួលបានសុខភាពល្អ សុភមង្គល និងសម្រេចបាននូវភាពជោគជ័យគ្រប់ភារកិច្ច ។